ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តព្រះវិហារ

-សំណុំរឿងរដ្ឋប្បវេណីលេខ ២១
ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១

# សាលក្រម

លេខ:០១(យ)

ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងខេត្តព្រះវិហារ**

-បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១ នៅម៉ោង៨និង៣០នាទីព្រឹក លើសំណុំរឿងរដ្ឋប្បវេណីលេខ:២១ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២១ ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តព្រះវិហារ

**ក្រឡាបញ្ជី**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តព្រះវិហារ

-រវាងដើមចោទ ក្រុមហ៊ុន [redacted] ( [redacted] តំណាងដោយ លោកស្រី [redacted] សំណាង មានតួនាទីជាប្រធានគ្រប់គ្រងទីផ្សា អាសយដ្ឋាន [redacted]។

-លោក [redacted] លោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ អាសយដ្ឋានផ្ទះលេខ: [redacted]។

-និងចុងចម្លើយ ឈ្មោះ [redacted] ជាឡៃទ្បេន ភេទស្រី អាយុ៣៩ឆ្នាំ ជនជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ លេខ ២២០១២១២១២ មានអាសយដ្ឋាននៅ [redacted]។

-លោក [redacted] និងលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយ អាសយដ្ឋានផ្ទះលេខ: [redacted]។

**អង្គហេតុ និងចំណុចវិវាទ**

**ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ**

ក/បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ជាឡៃទ្បេន សង់ប្រាក់មកឲ្យដើមចោទនូវប្រាក់ដើមចំនួន USD ២៤៥៦,៨៧ (ពីរពាន់បួនរយហាសិបប្រាំមួយ ដុល្លារអាមេរិក និងសែសិបប្រាំពីរសេន)។

ខ/បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ជាឡៃទ្បេន សងការប្រាក់ឲ្យដើមចោទចំនួន ១៨%(ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ព្រះវិហារ.ថ្ងៃទី...២៧ ខែ...ឆ្នាំ២០២១
ក្រឡាបញ្ជី

[redacted]

Scanned with CamScanner

គ/ទាមទារសំណងជម្ងឺចិត្ត ការខូចខាតពេលវេលា និងសេវាកម្មច្បាប់ចំនួន USD ៥,០០០០(ប្រាំម៉ឺនដុល្លារ អាមេរិក) ពីចុងចម្លើយឈ្មោះ [redacted] ដាវ៉ែឡុន។

ឃ/ស្នើសុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន។

ង/បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ដាវ៉ែឡុន បង់ពន្ធប្រាក់ប្រដាប់ក្តី និងពន្ធដាក់ពាក្យសុំ។

**ខ.ដំណើររឿងក្តី និងចំណុចវិវាទ**

ខ.១.ការសង្ខេបអំពីរឿងក្តី

តាមពាក្យបណ្តឹងដែលដើមចោទបានដាក់មកតុលាការដោយមូលហេតុថា កាលពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ឈ្មោះ [redacted] ដាវ៉ែឡុន ជាម្ចាស់ដេប៉ូឈ្មោះ [redacted] បានកម្មង់ទំនិញពី ក្រុមហ៊ុន [redacted] ( [redacted] ចំនួនពីរដំណាក់កាល ដោយលើកទី១ នៅថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៩ មានចំនួន២៦៣៥.០០$ (ពីរពាន់ប្រាំមួយ រយសាមសិបប្រាំដុល្លា អាមេរិក) ដែលមានវិក័យបត្រលេខ ១៩០០០៣៧ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ដោយការព្រមព្រៀងកំណត់ពេលទូទាត់ប្រាក់រយះពេល១ខែ(មួយខែ)។ មកដល់ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩ ចុងចម្លើយបានទូទាត់ប្រាក់ដែលជំពាក់ក្រុមហ៊ុននៅក្នុងវិក័យបត្រលេខ ១៩០០០៣៧ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ សរុបចំនួន ១៦៧៩.០០$ (មួយពាន់ប្រាំមួយរយចិតសិបប្រាំបួនដុល្លា អាមេរិក) ចំណែកទឹកប្រាក់ដែលចុងចម្លើយមិនទាន់ទូទាត់បំណុលឲ្យមកដើមចោទ មានចំនួន ៩៥៦.០០$ (ប្រាំបួនរយហាសិបមួយដុល្លាអាមេរិក)។

នៅលើកទី២ នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ ភាគីចុងចម្លើយបានទំនាក់ទំនងមកខាងក្រុមហ៊ុន ដើម្បីសុំកម្មង់មុខ ទំនិញម្តងទៀត ដែលមានវិក័យបត្រលេខ ១៩០០១៤៤ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ មានទឹកប្រាក់សរុបចំនួន៥២០០.០០$ (ប្រាំពាន់ពី រយដុល្លាអាមេរិក) ដែលមានរយះពេលការទូទាត់ប្រាក់រយះពេល ៣ខែ ។

ហេតុមកដល់ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ ខាងចុងចម្លើយ បានបង់ប្រាក់មកក្រុមហ៊ុនមានចំនួនទឹកប្រាក់សរុបតែ២២៧៦,២៩$ (ពីរពាន់ពីររយចិតសិបប្រាំមួយ ដុល្លាអាមេរិកនិងម្ភៃប្រាំបួនសេន) ហើយបានធ្វើការបង្វិល ឥវ៉ាន់ដែលបាន កម្មង់ពីខាងក្រុមហ៊ុនមួយចំនួនមកឲ្យវិញផង។

ចំពោះទឹកប្រាក់សរុបដែលចុងចម្លើយនៅខ្វះដើមចោទ សម្រាប់ដំណាក់កាលទី១ និងទី២ សរុបចំនួន ៣២៣២,២៩$ (បីពាន់ពីររយសាមសិបពីរដុល្លាអាមេរិក និងម្ភៃប្រាំបួនសេន)។

នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ ចុងចម្លើយបានធ្វើកិច្ចសន្យាទូទាត់លុយជា មួយ ដើមចោទ ក្នុងកិច្ចសន្យាភាគីដើមចោទបានទុកពេលអោយចុងចម្លើយរយះពេល ៦ខែ អោយទូរ ទាត់ប្រាក់សរុបចំនួន ៣២៣២,២៩$ តែចុងចម្លើយបានទូរទាត់អោយដើមចោទ បានតែចំនួន ៧៧៥,៨៤$ ប៉ុណ្ណោះ ហើយនៅខ្វះប្រាក់សរុបចំនួន ២៤៥៦,៤៧ $ (ពីរពាន់បួនរយហាសិបប្រាំ មួយ និងសែសិបប្រាំពីរសេន)។

លុះមកដល់ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២១ ដើមចោទបានចុះទៅចរចារ និងធ្វើការជូន ដំណឹងដាស់តឿនអោយចុងចម្លើយទូទាត់ប្រាក់ តែភាគីចុងចម្លើយព្រងើយកន្តើយ និងគេច វេសមិនព្រមសងប្រាក់នៅជំពាក់ឡើយ ដែលនេះជាការបំពានកាតព្វកិច្ចនៃកិច្ចសន្យា និងមាន ចេតនាទុច្ចរិត ក្នុងការមិនព្រមសងប្រាក់ ទើបកូនក្តីយើងខ្ញុំបានប្តឹងមកតុលាការដើម្បីទាមទារប្រាក់នេះ។

ខ.២.ការអះអាងរបស់គូភាគី

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ព្រះវិហារ.ថ្ងៃទី...ខែ...ឆ្នាំ២០២២

ក្រឡាបញ្ជី

[redacted]

-មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា៖ កូនក្តីខ្លួននៅតែទាមទារដូចមានក្នុងបណ្តឹង ចុះថ្ងៃទី០១ ខែមិនា ឆ្នាំ២០២១ទុកជា បាន ការដដែល។ ចុងចម្លើយបានចុះកិច្ចសន្យាថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២១ ដោយមានផ្តិត ស្នាមម្រាម ដៃផង ដែរដើម្បីទូទាត់ប្រាក់សរុបចំនួន៣២៣២.២៩$ សម្រាប់រយៈពេលសង៦ខែឲ្យមកដើមចោទតែចុងចម្លើយទូទាត់បានតែ ចំនួន ៧៧៥,៨$ ប៉ុណ្ណោះ ហើយនៅខ្វះប្រាក់សរុបចំនួន ២៤៥៦,៤៧$ ដែលដើមចោទត្រូវទាមទារ។ នៅក្នុងការធានាការអនុវត្តន៍កិច្ចសន្យានេះ ចុងចម្លើយបានយល់ព្រមបង់ការប្រាក់ត្រូវគិតតាមការកំណត់របស់ធនាគារ អេស៊ីលីដា ដូច្នេះដើមចោទស្នើសុំទូទាត់ការប្រាក់ចំនួន១៨%(ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ រហូតដល់សងគ្រប់ចំនួន។ ចំពោះការទាមទារសំណងការខូចខាត ពេលវេលា ជំងឺចិត្ត និងសេវាច្បាប់ ចំនួន ៥០.០០០$ ដោយហេតុថា ចុងចម្លើយមិនបានអនុវត្តកាតព្វកិច្ច និងតែងតែគេចវេសមិនសងប្រាក់ ទើបធ្វើឲ្យដើមចោទខូចខាត ពេលវេលា ជំងឺចិត្ត និងសេវាច្បាប់ ដូច្នេះដើមចោទ នៅតែទាមទារប្រាក់នេះដដែល។ ចំពោះការអនុវត្តសាលក្រមជាបណ្តោះអាសន្ននេះ ដោយសារ ភាគីបានចុះកិច្ចសន្យាច្បាស់លាស់ដែលជាកស្តុតាងមិនអាចកែប្រែបាន ទោះបីប្តឹងទៅតុលាការជាន់ខ្ពស់ក៏ដោយក៏ការសម្រេចមិនអាចធ្វើការកែប្រែឡើយ ដូច្នេះដើមចោទនៅតែស្នើសុំអនុវត្តសាលក្រមបណ្តោះអាសន្នដ៏ដែល។

-មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា៖ ចំណុច ក ដែលមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទទាមទារ កូនក្តីខ្លួនទទួលស្គាល់ប្រាក់ដើមដែលជំពាក់ក្រុមហ៊ុនចំនួន ១៩៥៦ (មួយពាន់ប្រាំបួនរយហាសិបប្រាំមួយ)ដុល្លារអាមេរិក ដោយក្រុមហ៊ុន បានអនុញ្ញាតឲ្យកូនក្តីខ្លួនលើកផ្លាកយីហោ អស់ប្រាក់ចំនួន ៥០០(ប្រាំរយ)ដុល្លារអាមេរិក។ ចំណុច ខ ក្រុមហ៊ុនបានបង្គាប់ឲ្យកូនក្តីរបស់ខ្លួន បង់ការប្រាក់ឲ្យដើមចោទចំនួន ១៨%(ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងគ្រប់ចំនួន សុំច្រានចោល ដោយក្នុងរឿងនេះកូនក្តីរបស់ខ្លួនពុំបានជំពាក់ប្រាក់របស់ក្រុមហ៊ុននោះទេ គឺក្រុមហ៊ុនទេ ដែលស្នើសុំយកអ៊ីវ៉ាន់ដាក់ក្នុងឃ្លាំងកូនក្តីរបស់ខ្លួន ដោយឲ្យកូនក្តីរបស់ខ្លួនលក់ចំនេញជាក្បាលកាក់ ហើយបានទូទាត់ឲ្យក្រុមហ៊ុនម្តង។ ចំណុច គ ដើមចោទទាមទារសំណងជម្ងឺចិត្ត ការខូចខាតពេលវេលា និងសេវាកម្មច្បាប់ចំនួន USD ៥,០០០០(ប្រាំម៉ឺនដុល្លារអាមេរិក) ពីកូនក្តីខ្លួន សុំច្រានចោល ដោយសារតែទំនិញដែលបានដាក់នៅក្នុងឃ្លាំងបណ្តាលឲ្យខូចខាតពុកផុយឃ្លាំង កូនក្តីរបស់ខ្លួនមិនបានទាមទារឲ្យសងនោះទេ ដោយខាងកូនក្តីរបស់ខ្លួនគាត់ខ្សែជន់។ ចំណុច ឃ ស្នើសុំអនុវត្តសាលក្រមជាបណ្តោះអាសន្ន កូនក្តីខ្លួនសុំបដិសេធ ព្រោះឃ្លាំងកូនក្តីខ្លួន តម្លៃគឺលើសប្រាក់ជំពាក់នោះទៅទៀត។

ខ.៣.ចំណុចវិវាទ

មិនឯកភាពគ្នាលើ:

-ប្រាក់ដើមចំនួន USD២៤៥៦,៤៧ (ពីរពាន់បួនរយហាសិបប្រាំមួយដុល្លារអាមេរិក និងសែ សិបប្រាំពីរសេន)។

-ការសងការប្រាក់ចំនួន១៨% (ដប់ប្រាំបីភាគរយ)ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងគ្រប់ចំនួន។

-សំណងជម្ងឺចិត្ត និងសេវាកម្មច្បាប់ចំនួន USD ៥,០០០០ (ប្រាំម៉ឺនដុល្លារអាមេរិក)។

-បានឃើញ ពាក្យបណ្តឹង ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១។

ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ព្រះវិហារ.ថ្ងៃទី...ខែ...ឆ្នាំ២០២១
ក្រឡាបញ្ជី

[redacted]

-បានឃើញ កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១។

-បានឃើញ កំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១។

-ក្រោយពីបានស្តាប់មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទថ្លែងការណ៍ និងប្តឹងសុំ។

-ក្រោយពីបានស្តាប់មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយថ្លែងការណ៍។

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១/-ពាក្យបណ្តឹង ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ របស់អ្នកតំណាងឲ្យដើមចោទឈ្មោះ [redacted] សំណាង ធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមទម្រង់អាចឲ្យតុលាការយកមកចាត់ការបាន។

២/-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយណត្តិឲ្យដើមចោទ, ស្តាប់សេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយណត្តិឲ្យចុងចម្លើយ ,និងបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយបដិសេធទាំងស្រុង។

៣/-ការវិនិច្ឆ័យអំពីការទាមទារ

-មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ទាមទារប្រាក់ ជំពាក់ ២៤៥៦,៤៧(ពីរពាន់បួនរយហាសិបកៀសសែសិបប្រាំបី)ដុល្លារអាមេរិក ដោយផ្អែកលើកិច្ចសន្យា ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ ,វិក័យបត្រទិញអីវ៉ាន់លេខ ១៩០០០៣៧ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩ ,វិក័យបត្រទិញអីវ៉ាន់លេខ ១៩០០១៤៤ ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ និងបញ្ជីទូទាត់ប្រាក់ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ តែមេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយទទួលស្គាល់ប្រាក់នៅជំពាក់តែចំនួន១៩៥៦(មួយពាន់ប្រាំបួនរយហាសិបប្រាំមួយ)តែប៉ុណ្ណោះ ដោយអះអាងថា ដើមចោទឲ្យកូនក្តីខ្លួនធ្វើផ្លាកយីហោ ហើយផ្លាកនោះត្រូវការចំណាយប្រាក់អស់ ៥០០$ តែដើមចោទបែជាថាផ្លាកយីហោនោះអស់ ៣០០$ ទៅវិញហេតុនេះ គប្បីតុលាការពិចារណាសម្រេច។

-មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ទាមទារឲ្យចុងចម្លើយសងការប្រាក់ចំនួន១៨% ក្នុងមួយឆ្នាំ គិតចាប់ពីថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៩ រហូតដល់ថ្ងៃសងគ្រប់ចំនួន ដោយផ្អែកដោយផ្អែកលើកិច្ចសន្យា ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២១ មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយច្រានចោលការបង់ការប្រាក់នេះ ព្រោះវាមិនមែនជាកិច្ចសន្យាខ្ចីបរិភោគ ឬកិច្ចសន្យាចងការប្រាក់ វាជាការរកស៊ីជាមួយក្រុមហ៊ុនដែលបានដាក់អីវ៉ាន់ឲ្យកូនក្តីខ្លួនលក់ចំណេញតែក្បាលកាក់ប៉ុណ្ណោះ គប្បីតុលាការពិចារណាតាមច្បាប់។

-មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទ ទាមទារឲ្យចុងចម្លើយ សងសំណងជម្ងឺចិត្ត ការខូចខាតពេលវេលា និងសេវាកម្មច្បាប់ចំនួន ៥០០០០(ប្រាំម៉ឺន)ដុល្លារអាមេរិក មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយច្រានចោលការទាមទារនេះ ព្រោះកូនក្តីខ្លួនបានក្ស័យធនក្នុងការរកស៊ីនេះ គប្បីតុលាការពិចារណាតាមច្បាប់។

៤/-ស្តីពីការប្រកាសឲ្យអនុវត្តជាបណ្តោះ

-មេធាវីតំណាងដោយអាណត្តិឲ្យដើមចោទទាមទារឲ្យអនុវត្តជាបណ្តោះអាសន្នដោយផ្អែក តាមកិច្ចសន្យា ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ មេធាវីតំណាងដោយអាណត្តិឲ្យចុងចម្លើយបដិសេធព្រោះមិនសម

ថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ព្រះវិហារ ថ្ងៃទី ១៣ ខែ ... ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]

[illegible] ហើយ[illegible]យល់ឃើញថា មានភាពចាំបាច់ ដូច្នេះប្រកាសថា ការទាមទារលើប្រាក់ដើមអាចអនុវត្តជាបណ្ដោះអាសន្ន។

៥-ស្ដីពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី

ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់គូភាគី គប្បីតុលាការសម្រេចតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ហេតុដូច្នេះ**

**សម្រេចសេចក្ដីបញ្ចប់**

១.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ជាខ្សែន ភេទស្រី អាយុ៣៩ឆ្នាំ សងប្រាក់ដើមចំនួន USD ១៩៥៦ (មួយពាន់ប្រាំបួនរយហាសិបប្រាំមួយ)ដុល្លារអាមេរិក ទៅឲ្យដើមចោទ។

២.បង្គាប់ឲ្យចុងចម្លើយសងប្រាក់ជម្ងឺចិត្ត និងសេវាកម្មច្បាប់ចំនួនចំនួន USD ៥០០០ (ប្រាំពាន់)ដុល្លារអាមេរិក ទៅឲ្យដើមចោទ។

៣.ច្រានចោលការទាមទារអត្រាការប្រាក់ចំនួន ១៨% (ដប់ប្រាំបីភាគរយ)ក្នុងមួយឆ្នាំ។

៤.សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នត្រង់ចំណុចទី១។

៥.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

ក្នុងការណីដែលប្ដឹងឧទ្ធរណ៍រយៈពេល០១(មួយ)ខែ គិតចាប់តាំងពីថ្ងៃដែលទទួលបានការបញ្ជូនលិខិតសាលក្រមនេះ។

ថ្ងៃអង្គារ ០៦កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ខេត្តព្រះវិហារ,ថ្ងៃទី១២ ខែតុលា ឆ្នាំ២០២១

ចៅក្រមជំនុំជម្រះ

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ព្រះវិហារ ថ្ងៃទី.១៣ខែ.[illegible]...ឆ្នាំ២០២១

ក្រឡាបញ្ជី

[redacted]